# ព្រះរាជក្រឹត្យ



## ស្ដីពី

## ការបង្កើតសហគមន៍នេសាទ

# អនុក្រឹត្យ

## ស្ដីពី

## ការគ្រប់គ្រងសហគមន៍នេសាទ

បោះពុម្ពផ្សាយដោយ : រដ្ឋបាលជលផល
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

# ព្រះរាជក្រឹត្យ

# ស្ដីពី

# ការបង្កើតសហគមន៍នេសាទ


AIDOC

Code: 142-020

Date:

Donated by:

នស/រកត/០៥០៥/២៤០

# ព្រះរាជក្រឹត្យ

## ស្តីពី

## ការបង្កើតសហគមន៍នេសាទ

៙❖៚

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា**
**សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែង តាំងរាជរដ្ឋាភិបាល នៃព្រះ រាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈ រដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ដែលបានការឯកភាពពី គណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញ អង្គ នៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០០៥

## ត្រាស់បង្គាប់

**មាត្រា ១.** _

ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានសិទ្ធិរួមគ្នាបង្កើតសហគមន៍នេសាទនៅតាមមូលដ្ឋានរបស់ខ្លួន ដោយឈរលើគោលការណ៍ស្ម័គ្រចិត្ត និងមានគំនិតផ្តួចផ្តើមបង្កើនជីវភាពរស់នៅរបស់ខ្លួន តាមរយៈការប្រើប្រាស់ធនធានជលផលប្រកបដោយចីរភាព ដើម្បីរួមចំណែកលើកតម្កើងសេដ្ឋកិច្ចសង្គមកិច្ច និងកាត់បន្ថយភាពក្រីក្រ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសមត្ថកិច្ចទូទៅលើការគ្រប់គ្រងសហគមន៍នេសាទ ។

**មាត្រា ២.** _

សហគមន៍នេសាទត្រូវមានលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ផែនការគ្រប់គ្រង ផែនទីកន្លែងនេសាទសហគមន៍របស់ខ្លួន និងកិច្ចព្រមព្រៀងដែលមានការទទួលស្គាល់ពីអាជ្ញាធរមានសមត្ថកិច្ច ។

**មាត្រា ៣.** _

សហគមន៍នេសាទដែលមានដែននេសាទជាប់គ្នា អាចចូលរួមជាមួយគ្នាដោយបង្កើតជាសហព័ន្ធសហគមន៍នេសាទបាន ។

វិធាន និងនីតិវិធីដើម្បីបង្កើត និងគ្រប់គ្រងសហគមន៍នេសាទ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៤.** _

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥.** _

នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ , ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣រស.០៥០៥.២៥៥

**បានយកសេចក្តីក្រាបបង្គំទូលថ្វាយ**

**ព្រះមហាក្សត្រសូមឡាយព្រះហស្តលេខា**

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ: ២១៧ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ២០០៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណាវី តាន់**

# អនុក្រឹត្យ

# ស្ដីពី

# ការគ្រប់គ្រងសហគមន៍នេសាទ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ ២៥ អនក្រ.បក**

# អនុក្រឹត្យ

# ស្តីពី

# ការគ្រប់គ្រងសហគមន៍នេសាទ

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៤០ ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៥ ស្តីពីការបង្កើតសហគមន៍នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីការប្តូរឈ្មោះនាយកដ្ឋានជលផលទៅជារដ្ឋបាលជលផល
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០០ អនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០១ អនុក្រឹត្យលេខ ០៦ អនក្រ.បក លេខ ០៧ អនក្រ.បក លេខ ០៨ អនក្រ.បក លេខ ០៩ អនក្រ.បក លេខ ១០ អនក្រ.បក ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០១ អនុក្រឹត្យលេខ ១៩ អនក្រ.បក លេខ ២១ អនក្រ.បក លេខ ២២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០១ អនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី១៩ ខែ កុម្ភៈ ឆ្នាំ ២០០១ អនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០១ អនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០១ និងអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ស្តីពីការលុបនាទីឡូត៍នេសាទ និងការកាត់បន្ថយដែននេសាទក្នុងនាទីឡូត៍នេសាទក្នុងខេត្តបាត់ដំបង ខេត្តកំពង់ធំ ខេត្តកណ្តាល ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ចាម រាជធានីភ្នំពេញ ខេត្តក្រចេះ ខេត្តព្រៃវែង និងខេត្តតាកែវទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.** –

អនុក្រឹត្យនេះមានវិសាលភាព និងគោលដៅកំណត់អំពីវិធាន និងនីតិវិធីដើម្បីបង្កើត និងគ្រប់គ្រងសហគមន៍នេសាទ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.** –

អនុក្រឹត្យនេះមានគោលបំណង ៖

- គ្រប់គ្រងដែននេសាទទឹកសាបដែលបានលុប ឬកាត់បន្ថយពីនាទីឡូត៍នេសាទ កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទ កន្លែងនេសាទបម្រុង ទំនាបលិចទឹកក្នុងរដូវជំនន់ឡើង នាទីព្រៃលិចទឹក និងព្រៃកោងកាង និងកន្លែងនេសាទតាមឆ្នេរ
- គ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងធានាការបែងចែកផលប្រយោជន៍ពីធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ធ្វើឱ្យប្រជាពលរដ្ឋខ្មែរបានយល់ដឹង និងទទួលស្គាល់កាន់តែច្បាស់ឡើងនូវផលប្រយោជន៍ និងសារៈសំខាន់នៃធនធានជលផលតាមរយៈការចូលរួមគ្រប់គ្រង ប្រើប្រាស់ និងការពារធនធានជលផលដោយផ្ទាល់
- ផ្តល់ក្របខ័ណ្ឌច្បាប់សម្រាប់បង្កភាពងាយស្រួលជូនដល់ប្រជាពលរដ្ឋខ្មែរនៅតាមមូលដ្ឋានក្នុងការបង្កើតសហគមន៍នេសាទ
- លើកស្ទួយកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋខ្មែរដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រ ។